# សមត្ថភាពស្នូលសម្រាប់វគ្គបណ្តុះបណ្តាលស្តីពីការងារតាមដានសង្កេតសុខភាពសត្វព្រៃ

សម្រាប់ខ្មទ្បានុក្ស (ឆ្មាំព្រៃ)

ផ្នែកទី ១៖ ចំណេះដឹងអំពីសុខភាពសត្វព្រៃ

ឆ្មាំព្រៃមានសមត្ថភាព៖

1.1. យល់ដឹងអំពីគោលគំនិតជាមូលដ្ឋានអំពីសុខភាពសត្វព្រៃ ព្រមទាំងទំនាក់ទំនងរវាងសុខភាពសត្វព្រៃ ទៅនិងសុខភាពរបស់គ្វចិញ្ចឹម ក៏ដូចជាសុខភាពរបស់ខ្លួនពួកគេផ្ទាល់ផងដែរ ។

1.2. យល់ដឹងអំពីតួនាទីដែលខ្លួនត្រូវបំពេញក្នុងការងារតាមដានសង្កេតសុខភាពសត្វព្រៃ

1.3. យល់ដឹងថាតើមាន ប៉ាតូហ្សែន អ្វីខ្លះ និងមូលហេតុចំបងៗដែលបណ្តាលឲ្យជម្ងឺឆ្លងរីករាលដាល

ផ្នែកទី ២៖ ការសិក្សាវាយតម្លៃ និងវិភាគអំពីហេតុការណ៍អ្វីមួយ

ឆ្មាំព្រៃមានសមត្ថភាព៖

2.1. ចេះពីរបៀបវាយតម្លៃអំពីស្ថានភាពដែលមានសត្វព្រៃងាប់ រួចកំណត់ថាតើទីកន្លែងនោះមានសុវត្ថិភាព អាចចូលទៅត្រួតពិនិត្យ និងស៊ើបអង្កេតលម្អិតបានដែរឬយ៉ាងណា ។

2.2. បំពេញឯកសារ និងចងក្រងព័ត៌មានឲ្យបានសុក្រិតបំផុតអំពីទិដ្ឋភាព និងសត្វ ។

ផ្នែកទី ៣៖ របៀបថែរក្សាសុវត្ថិភាពផ្ទាល់ខ្លួន

ឆ្មាំព្រៃមានសមត្ថភាព៖

3.1. យល់ដឹងថាអ្នកណាដែលត្រូវស្លៀកពាក់សម្លៀកបំពាក់ការពារខ្លួន (PPE) នៅពេលយកសំណាកសត្វ ។

3.2. យល់ដឹងថាហេតុអ្វីបានជាគេចាំបាច់ត្រូវពាក់ម៉ាស់ អៀម ស្រោមដៃ វ៉ែនតាការពារការឆ្លងជម្ងឺពីសត្វ និងប្រភពមេរោគ ។

3.3 របៀបស្លៀកពាក់ និងដោះសម្លៀកបំពាក់ PPE ឲ្យបានត្រឹមត្រូវ និងតាមលំដាប់លំដោយ ។

3.4 របៀបបោះចោលឲ្យបានត្រឹមត្រូវនូវសម្លៀកបំពាក់ PPE ដែលប្រឡាក់ប្រឡូក ។

ផ្នែកទី ៤៖ ការអនុវត្តតាមគោលការណ៍

ឆ្មាំព្រៃមានសមត្ថភាព៖

4.1. រាយការណ៍អំពីហេតុការណ៍ដែលមានករណីសត្វព្រៃ ឈឺ/ងាប់ ទៅកាន់មន្ត្រីទទួលបន្ទុកដោយអនុលោមតាមគោលការណ៍ក្រមប្រតិបត្តិស្តង់ដា (SOP) សម្រាប់ការតាមដានសុខភាពសត្វព្រៃ (ឬគោលការណ៍ណែនាំផ្សេងៗទៀត) ។

4.2. រាយការណ៍អំពីហេតុការណ៍ដែលមានករណីសត្វព្រៃ ឈឺ/ងាប់ ជាបន្ទាន់ភ្លាម បើសិនមានសញ្ញាបញ្ជាក់ថាករណីនោះជាករណីបន្ទាន់ (ដូចជាមានសត្វងាប់លើសពីមួយនៅក្នុងកន្លែងតែមួយដូចគ្នា)

**ផ្នែកទី ៥៖** ការយកសំណាក ការរក្សាទុក និងដឹកជញ្ជូន

ឆ្នាំព្រៃមានសមត្ថភាព៖

5.1. កំណត់ដឹងថាតើស្ថានភាពបែបណាដែលត្រូវយកសំណាក ។

5.2. របៀបយកសំណាកតាមមាត់ឲ្យបានត្រឹមត្រូវ និងមិនឲ្យសំឡីត្បារយកសំណាកនោះប្រឡូកប្រឡាក់

5.3. របៀបយកសំណាកតាមរន្ធច្រមុះ/រន្ធគូថឲ្យបានត្រឹមត្រូវ និងមិនឲ្យសំឡីត្បារយកសំណាកនោះប្រឡូកប្រឡាក់

5.4. របៀបយកសំណាកពីលាមកឲ្យបានត្រឹមត្រូវ

5.5. របៀបសរសេរស្លាកលើសំណាកឲ្យបានត្រឹមត្រូវ

5.6. របៀបវេចខ្ចប់សំណាកឲ្យបានត្រឹមត្រូវ និងប្រកបដោយសុវត្ថិភាព

5.7. របៀបច្រកសាកសពសត្វទាំងមូលឲ្យបានត្រឹមត្រូវ (ដោយមានទាំងទម្រង់របាយការណ៍អំពីសត្វឈឺ/ងាប់) និងប្រកបដោយសុវត្ថិភាព ។

5.8. យល់ដឹងអំពីគោលការណ៍គ្រឹះ និងសេចក្តីណែនាំសម្រាប់រក្សាប្រព័ន្ធត្រជាក់